# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

-សំណុំរឿងព្រហ្មទណ្ឌ លេខៈ ១៤៤១ អក
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២
-សាលក្រមលេខៈ **២៦** (យ)
ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះជាអសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមាន សមាសភាពដូចតទៅៈ

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា
លោកស្រី [redacted] ចៅក្រុមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤៤១ អក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ដែលមាន សាវតាជាតិជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សារឿន (រ) ម្តាយ ឈ្មោះ [redacted] ចន្ទូ (រ) នៅលីវ ទោសពីមុន គ្មាន។ (ឃុំខ្លួននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២)

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សីហា ។

ជាប់ចោទពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលត្រែអ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៧៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សំបូរ (រ) ម្តាយ ឈ្មោះ [redacted] សុខុម (រ) នៅលីវ ទោសពីមុន គ្មាន ។ (គេចខ្លួន)



Scanned with CamScanner

ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវាលគ្រែអ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៧៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ៦អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៥ និង ៣៥នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលតាលន់ បានសហការជាមួយកម្លាំងប្រជាការពារ ធ្វើការចេញល្បាតការពារសន្តិសុខជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន មកដល់ចំណុចផ្លូវលំ ស្ថិតក្នុងភូមិវាលគ្រែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល ក៏បានប្រទះឃើញជនសង្ស័យឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ កំពុងឈរនៅលើផ្លូវលំនោះ ដោយមានការសង្ស័យ កម្លាំងសមត្ថកិច្ចក៏បានឃាត់ត្រួតពិនិត្យ និងបានឆែកឆេរឃើញម្សៅក្រាមពណ៌សថ្លា ជាសារធាតុញៀន (ម៉ាទឹកកក) ចំនួន ប្រាំកញ្ចប់តូច នៅក្បែរខ្លួនជនសង្ស័យ បន្ទាប់មកកម្លាំងសមត្ថកិច្ចក៏ចាប់ឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] សីហា បញ្ជូនមកកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលតាលក់ ដើម្បីសាកសួរ ។ ជនសង្ស័យឈ្មោះ [redacted] សីហា បានឆ្លើយសារភាពថា ថ្នាំញៀន (ម៉ាទឹកកក) ចំនួនប្រាំកញ្ចប់តូចនេះ គឺឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ បានឱ្យមកខ្លួនដើម្បីទុកឱ្យវា។ ក្រោយឃាត់ខ្លួនសមត្ថកិច្ចក៏បានធ្វើតេស្តទឹកនោមលើជនសង្ស័យ ហើយលទ្ធផលបានបញ្ជាក់ថា មានសារធាតុញៀននៅក្នុងទឹកនោមនោះផងដែរ។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៤៥២ ដកសព ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ដែលប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ទៅជំនុំជម្រះ ។

**បានឃើញ** ដីកាដំណោះស្រាយលេខៈ ១៤៦៤ ដកដស ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ដែលសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ជួញដូរ , រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវាលគ្រែអ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៧៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សីហា បានឆ្លើយថា នៅថ្ងៃកើតហេតុប្រហែលជាម៉ោង បីរសៀល ខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] ឆៃយុទ្ធ ជិះដល់ពាក់កណ្តាលភូមិលេខ ៩ ឈ្មោះ [redacted] ឆៃយុទ្ធ បានហុចកញ្ចប់បារីឱ្យខ្លួន ក្នុងកញ្ចប់បារីនោះមានគ្រឿងញៀនចំនួន ប្រាំកញ្ចប់ ហើយគាត់បានឱ្យខ្លួនចុះពីលើម៉ូតូគាត់ និងរកម៉ូតូជិះទៅចាំគាត់នៅវត្តខន្តី។ ពេលនោះខ្លួនសុំបុរសម្នាក់មិនស្គាល់ឈ្មោះឱ្យគាត់ឌុបខ្លួនទៅវត្តខន្តី ពេលឌុបខ្លួនដល់ក្នុងវត្តខន្តី បុរសនោះក៏ទំលាក់ខ្លួនចុះហើយគាត់ជិះម៉ូតូចេញបាត់ទៅ ខ្លួនក៏ឈរចាំឈ្មោះ [redacted] ឆៃយុទ្ធ នៅទីនោះបានប្រហែល ដប់នាទី ស្រាប់តែសមត្ថកិច្ចមកដល់ ចាប់ខ្លួនឆែកឆេរមើលក៏ឃើញគ្រឿងញៀន ទាំងប្រាំកញ្ចប់ នៅក្នុងកញ្ចប់បារីដែលខ្លួនទុកនៅក្នុងហោប៉ៅខោ ហើយសមត្ថកិច្ចក៏នាំខ្លួនទៅសាកសួរនៅប៉ុស្តិ៍នគរបាលតែម្តង។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានដកហូតគ្រឿងញៀនចំនួនប្រាំកញ្ចប់ ក្រៅពីនេះមិនបានដកហូតអ្វីទេ។ ខ្លួនទទួលស្គាល់ថា ថ្នាំញៀនចំនួនប្រាំកញ្ចប់ ដែលសមត្ថកិច្ចដកហូតពីខ្លួន គឺខ្លួនបានមកពីឈ្មោះ [redacted] ឆៃយុទ្ធ ពិតប្រាកដមែន។ ពីមុនមកខ្លួនមិនដែលជួញដូរគ្រឿងញៀនទេ ហើយនៅថ្ងៃកើតហេតុក៏ខ្លួនមិនបានលក់គ្រឿងញៀនដែរ។



Scanned with CamScanner

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថាៈ ក្រោយពីបានសួរដេញដោលនាពេលសវនាការនេះ ដោយមានជនជាប់ចោទឈ្មោះ [redacted] សីហា នៅក្នុងឃុំ និងជនជាប់ចោទម្នាក់ទៀតឈ្មោះ [redacted] ផៃយុទ្ធ គេចខ្លួន។ នាពេលសវនាការ ជនជាប់ចោទឈ្មោះ[redacted] សីហា បានឆ្លើយសារភាពថា នៅថ្ងៃកើតហេតុ ខ្លួនបានជិះម៉ូតូជាមួយជនជាប់ចោទម្នាក់ទៀត ឈ្មោះ[redacted] ផៃយុទ្ធ ហើយជនជាប់ចោទឈ្មោះ[redacted] ផៃយុទ្ធ បានហុចកញ្ចប់បារីឱ្យជនជាប់ចោទឈ្មោះ [redacted] សីហា ដោយនៅក្នុងកញ្ចប់បារីនោះ គឺមានថ្នាំញៀនចំនួន ០៥កញ្ចប់។ ឈ្មោះ [redacted] សីហា ក៏ជាអ្នកប្រើប្រាស់គ្រឿងញៀនផងដែរ ដោយតាមរយៈការធ្វើតេស្តទឹកនោម ឃើញថា លទ្ធផលវិជ្ជមាន គឺមានសារធាតុញៀននៅក្នុងខ្លួន។ តាមលទ្ធផលកោសល្យវិច័យ ឃើញថា ថ្នាំញៀននោះជាប្រភេទមេតំហ្វេតាមីន ដែលមានធាតុសុទ្ធចំនួន ៧១,៤៧% នៃទម្ងន់សរុប ០,៤១ក្រាម។ តំណាងអយ្យការយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ និង ឈ្មោះ [redacted] ផៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ពីបទៈ ជួញដូរ , រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលត្រែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។ ហេតុនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានពិនិត្យ និងសិក្សាសំណុំរឿង និងក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សីហា ថា ខ្លួនមិនបានដឹងថា នៅក្នុងកញ្ចប់បារីនោះ មានគ្រឿងញៀននោះទេ។ ជនជាប់ចោទ ជាអនីតិជន មានកម្រិតនៃការចេះដឹងរបស់គាត់នៅមានកម្រិត ដោយគាត់រៀនបានត្រឹមតែថ្នាក់ទី២ប៉ុណ្ណោះ ធ្វើឱ្យគាត់មិនមានការគិតពិចារណាបានវែងឆ្ងាយ។ ហេតុនេះ ខ្ញុំស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណាផ្ដល់នូវស្ថានសម្រាលទោសឱ្យគាត់ ដោយគ្រប់នីតិវិធីរបស់តុលាការ គឺគាត់ទទួលស្គាល់នូវកំហុសរបស់ខ្លួន។

មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សីហា បានធ្វើសេចក្ដីសន្និដ្ឋានថា ខ្ញុំបាទសូមឯកភាពតាមការសន្និដ្ឋានរបស់សហភាគាទាំងស្រុង និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្ដល់នូវស្ថានសម្រាល និងបន្ធូរបន្ថយទោសឱ្យគាត់ ដើម្បីឱ្យគាត់ឆាប់បានចេញទៅកែខ្លួនជាបុគ្គលល្អនៅក្នុងសង្គមវិញ។

-សំដីចុងក្រោយរបស់ជនជាប់ចោទៈ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ព្រោះខ្លួនដឹងកំហុសដែលខ្លួនបានប្រព្រឹត្តហើយ ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

ក្រោយពីបានពិភាក្សាជាក្រុមប្រឹក្សារួចហើយ



Scanned with CamScanner

**<u>សាលាដំបូងខេត្តកណ្តាល</u>**

**<u>យល់ឃើញថា</u>**

-តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរលេខៈ **១១៩៩ ដកដស** ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០២២ បានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ជួញដូរ , រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវាលត្រែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សីហា បានឆ្លើយថា នៅថ្ងៃកើតហេតុប្រហែលជាម៉ោង បីរសៀល ខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] ឆៃយុទ្ធ ជិះដល់ពាក់កណ្តាលភូមិលេខ ៩ ឈ្មោះ [redacted] ឆៃយុទ្ធ បានហុចកញ្ចប់បារីឱ្យខ្លួន ក្នុងកញ្ចប់បារីនោះមានគ្រឿងញៀនចំនួន ប្រាំកញ្ចប់ ហើយគាត់បានឱ្យខ្លួនចុះពីលើម៉ូតូគាត់ និងរកម៉ូតូជិះទៅចាំគាត់នៅវត្តខន្តី។ពេលនោះខ្លួនសុំបុរសម្នាក់មិនស្គាល់ឈ្មោះឱ្យគាត់ឌុបខ្លួនទៅវត្តខន្តី ពេលឌុបខ្លួនដល់ក្នុងវត្តខន្តី បុរសនោះក៏ទំលាក់ខ្លួនចុះហើយគាត់ជិះម៉ូតូចេញបាត់ទៅ ខ្លួនក៏ឈរចាំឈ្មោះ [redacted] ឆៃយុទ្ធ នៅទីនោះបានប្រហែល ដប់នាទី ស្រាប់តែសមត្ថកិច្ចមកដល់ ចាប់ខ្លួនឆែកឆេរមើលក៏ឃើញគ្រឿងញៀនទាំងប្រាំកញ្ចប់ នៅក្នុងកញ្ចប់បារីដែលខ្លួនទុកនៅក្នុងហោប៉ៅខោ ហើយសមត្ថកិច្ចក៏នាំខ្លួនទៅសាកសួរនៅប៉ុស្តិ៍នគរបាលតែម្តង។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានដកហូតគ្រឿងញៀនចំនួនប្រាំកញ្ចប់ ក្រៅពីនេះមិនបានដកហូតអ្វីទេ។ ខ្លួនទទួលស្គាល់ថា ថ្នាំញៀនចំនួនប្រាំកញ្ចប់ ដែលសមត្ថកិច្ចដកហូតពីខ្លួន គឺខ្លួនបានមកពីឈ្មោះ [redacted] ឆៃយុទ្ធ ពិតប្រាកដមែន។ ពីមុនមកខ្លួនមិនដែលជួញដូរគ្រឿងញៀនទេ ហើយនៅថ្ងៃកើតហេតុក៏ខ្លួនមិនបានលក់គ្រឿងញៀនដែរ ។

-តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **១១៤៧** ដកសស ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្តាល បានធ្វើសេចក្តីសន្និដ្ឋានថាឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ពីបទៈ **ជួញដូរ , រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវាលត្រែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពិតប្រាកដមែន។

-តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ហេតុនេះតុលាការ នឹងធ្វើការពិចារណាពីបញ្ហានេះ។

-មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងរវាងចម្លើយជនជាប់ចោទ, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល និងតាមការពិនិត្យឯកសារភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងបញ្ជាក់ថា កាលពីថ្ងៃ២៨ ខែកញ្ញា ឆ្នាំ២០២២ ជនជាប់ចោទឈ្មោះ [redacted] សីហា ពិតជាបានប្រព្រឹត្តអំពើ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** និងឈ្មោះ [redacted] ឆៃយុទ្ធ ពិតជាបានប្រព្រឹត្តអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន ។

-ជនជាប់ចោទឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ឆៃយុទ្ធ ជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ និងជាសមត្ថជនដែលមានការពិចារណាយល់ដឹងអំពីផលវិបាក ដែលកើតចេញពីអំពើរបស់



Scanned with CamScanner

ខ្លួន ដែលស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដែលបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ពីបទ: ជួញដូរ, រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលត្រែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៧៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-នៅក្នុងសំណុំរឿងនេះ វត្ថុចាប់យកបញ្ជូនមកតុលាការមានម្សៅក្រាមពណ៌ស ជាសារធាតុញៀនប្រភេទម៉ាទឹកកកចំនួន ០៥ (ប្រាំ) កញ្ចប់ ទម្ងន់ ០,៤១ ក្រាម វេចខ្ចប់ដាក់ក្នុងស្រោមសំបុត្រធំ ពណ៌គគីរ បិទជិត ចំនួនមួយគ្មានលេខកូដ គប្បីតុលាការសម្រេចរឹបអូស តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣៩២៥៦/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ ឃើញថាលទ្ធផលវិជ្ជមាន វត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដោយបរិមាណ សារធាតុមេតំហ្វេតាមីន គិតជាភាគរយ នៃទម្ងន់ គឺ ៧១,៤៧ % ដូច្នេះ បរិមាណនៃធាតុសុទ្ធនៃមេតំហ្វេតាមីន គឺ ០,៤១ X ៧១,៤៧/១០០=០,២៩g(សូន្យក្បៀសម្ភៃប្រាំបួនក្រាម)។ តុលាការនឹងយកលទ្ធផលនេះជាមូលដ្ឋានក្នុងការផ្តន្ទាទោសជនជាប់ចោទ។

-ជនជាប់ចោទឈ្មោះ [redacted] សីហា ជាអនីតិជន មានអាយុ ១៧ឆ្នាំ ហេតុដូច្នេះ គប្បីតុលាការពិចារណាលើការផ្តន្ទាទោសជនជាប់ចោទរូបនេះ ដោយផ្តល់នូវស្ថានសម្រាលទោសឱ្យជនជាប់ចោទ តាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

## **ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖

១.១-ឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ។

ពីបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលត្រែអ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១.២-ឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦ ០០០ ០០០(ប្រាំមួយលាន)រៀល សម្រាប់ដាក់ចូលជាថវិកាជាតិរដ្ឋ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលត្រែង ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បង្គាប់ឱ្យចាប់-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ឆៃយុទ្ធ ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារខេត្តកណ្តាល គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

៣-វត្ថុតាងរួមម្សៅក្រាមពណ៌សជាសារធាតុញៀនប្រភេទម៉ាទឹកកកចំនួន ០៥ (ប្រាំ) កញ្ចប់ ទម្ងន់ ០,៤១ ក្រាម វេចខ្ចប់ដាក់ក្នុងស្រោមសំបុត្រធំ ពណ៌គគីរ បិទជិត ចំនួនមួយគ្មានលេខកូដ សម្រេចរឹបអូស តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

-សាលក្រមនេះជំនុំជំរះ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]សីហា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ផៃយុទ្ធ។

ទុកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃពុធ ៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]